ព្រឹត្តិបត្រអង្គការស្ត្រីខ្មែរកម្ពុជាក្រោម
Khmer Kampuchea Krom Women Organization Bulletin

ចេញផ្សាយប្រចាំត្រីមាស លេខ០៧ ឆ្នាំទី១ ពីថ្ងៃទី០១-១៥ ខែវិច្ឆិកា ឆ្នាំ២០០៨

ក្រុមកីឡាករទូក-ងខ្មែរកម្ពុជាក្រោមមានជ័យ
បាត់ត្រៀមចូលរួមប្រណាំងទូកព្រះរាជពិធីបុណ្យអុំទូកនាពេលខាងមុខនេះ

ជារៀងរាល់ឆ្នាំ ឱ្យតែដល់ខែវិច្ឆិកា នាថ្ងៃកាលនៃព្រះរាជពិធីបុណ្យអុំទូក អកអំបុក សំពះព្រះខែ និងបណ្តែតប្រទីប នៅព្រះរាជាណាចក្រកម្ពុជា តែងតែមានពិធីប្រណាំងទូក-ង ដោយមានការចូលរួមប្រណាំងទូកទាំងប្រទេស មានទៅដល់រាប់រយទូកឯណោះ។ ពួកបងប្អូនខ្មែរកម្ពុជាក្រោម ដែលមករស់នៅលើទឹកដីនៃព្រះរាជាណាចក្រកម្ពុជា ដោយមានការឧបត្ថម្ភពីសហព័ន្ធខ្មែរកម្ពុជាក្រោមពិភពលោក និងសង្គម-សមាគមខ្មែរកម្ពុជាក្រោមនៅកម្ពុជា ព្រមទាំងបងប្អូនសប្បុរសជននានាទាំងក្នុង និងក្រៅប្រទេស ក៏បានបង្កើតក្រុមកីឡាករទូក-ង ដើម្បីចូលរួមប្រណាំងតាំងពីឆ្នាំ២០០២ រហូតដល់ឆ្នាំ២០០៨នេះ គឺមានគ្រប់ប្រាំលើកមកហើយដែរ។ ហើយនេះក៏ជាការចូលរួមលើកស្ទួយនូវវប្បធម៌ ប្រពៃណី ទំនៀមទម្លាប់របស់ជាតិខ្មែរយើង ដែលមានតាំងពីបុរាណកាលមកហើយ ដោយយើងធ្វើយ៉ាងណាកុំឱ្យប្រពៃណីទាំងអស់នេះបាត់បង់សាបសូន្យទៅវិញ គឺយើងត្រូវរួបរួមគ្នាជួយថែរក្សាទុក និងទុកឱ្យកូនចៅជំនាន់ក្រោយៗទៀត។

សកម្មភាពហ្វឹកហាត់របស់ក្រុមកីឡាករទូក-ងខ្មែរកម្ពុជាក្រោម

អាសយដ្ឋាន: ផ្ទះលេខ១៩ ផ្លូវ២៩៩ ក្រុម៦៨ សង្កាត់បឹងកេងកង១ ខណ្ឌចំការមន រាជធានីភ្នំពេញ

ទូរស័ព្ទ: ០១១ ៧១ ២៣ ២៥ / ០៩៩ ៩៧ ៩៥ ៨៣

E-mail: kkkwo@yahoo.com

ចែកជូនដោយឥតគិតថ្លៃ

ប្រវត្តិសង្ខេប នៃប្រពៃណីប្រណាំងទូក-ង

ប្រណាំងទូក-ង គឺជាទំនៀមទម្លាប់ប្រពៃណីជាតិខ្មែរតាំងពីបុរាណកាលមក ហើយ និងមានទំនៀមទម្លាប់ក្នុងស្រុកបាសាក់ ខេត្តឃ្លាំង (កម្ពុជាក្រោម) មកដល់សព្វថ្ងៃនេះ។ បើតាមថ្ងៃខែប្រណាំងទូក-ងនោះ បានពីនិយាយតាមលោកតាជីដូន គឺមិនមែនជាទូកសម្រាប់ប្រណាំងនោះទេ គឺជាទូកដើម្បីដឹកជញ្ជូនពលទាហានដើរទឹក ជារបស់ស្ដេចត្រាញ់ខ្មែរនៅ**ស្រុកបាសាក់**ពីបុរាណ។

រឿងរ៉ាវនេះបានរៀបរាប់តាមទំនៀមទម្លាប់ចាស់ ហើយត្រូវបានកត់ត្រាទុកនៅក្នុងរឿងទូក-ង មានក្នុងសៀវភៅប្រវត្តិសាស្ត្រ និងភូមិសាស្ត្រខ្មែរកម្ពុជាក្រោមស្រុក**បាសាក់** ខេត្ត **ឃ្លាំង** (**កម្ពុជាក្រោម**) ប្រវត្តិនោះបានបញ្ជាក់ថា ៖ កាលពីឆ្នាំព.ស ១៥២៨ ព្រះរាជាព្រះនាម **អង្គចន្ទទី១** ស្ដេចទាំងឡាយនៃខ្មែរជាធំ ក្នុងសម័យនោះ នៅស្រុកបាសាក់មានព្រះចៅអធិការវត្តឃ្លាំង **នេន** ធ្វើជាចៅហ្វាយស្រុក ព្រះនាម **អង្គចន្ទ** ព្រះរាជទាន ឈ្មោះ **ពញាមាស** ហៅថា (**ស៊ិន្ធុកុមារ**) ហើយព្រះរាជទានឱ្យមានតំណែងជាស្ដេចត្រាញ់ក្នុងស្រុកបាសាក់។

សកម្មភាពស៊ិន្ធុកុមារ

លោក **ស៊ិន្ធុកុមារ** នៅធ្វើស្ដេចត្រាញ់នៅស្រុក**បាសាក់**នោះ លោកបានរៀបចំស្រុកឱ្យមានជាកងទ័ព ហើយបានចែកចេញ ៤ នៅទិសទាំង ៤។ ជាក្រុមគេហៅថា **កង្វះ** ក្នុងសម័យនោះ ហើយតាំងឱ្យមានមន្ត្រីរក្សាទុកដូចតទៅ:

ទី១- *មន្ត្រីសេនាបរលេខ:* ត្រួតត្រាទិសខាងកើតតាមទន្លេបាសាក់ទៅដល់សមុទ្រ។

ទី២- *មន្ត្រីអធិករលេខ:* ត្រួតត្រាទិសខាងត្បូងតាមសមុទ្រ **ពលលាន** ដល់ **ក្រូចឆ្មារ**។

ទី៣- *មន្ត្រីអគ្គិរលេខ:* ត្រួតត្រាទិសខាងលិចតាមសមុទ្រ **ក្រូចឆ្មារ** ដល់ **ខេត្តឃ្លាំង**។

ទី៤- *មន្ត្រីសេនាបញ្ចរ:* ត្រួតត្រាទិសខាងជើងតាមមាត់ទន្លេបាសាក់ដល់ **មាត់ជ្រូក**។

សកម្មភាពរៀបចំក្បួនទូក

ក្នុងសម័យដែលរៀបចំមន្ត្រីឱ្យត្រួតត្រាទិសទាំង៤ នោះ លោក**ស៊ិន្ធុកុមារ**បានឱ្យរៀបក្បួនទ័ពទូកចម្បាំងដើរគោក និងជើងទឹក ក្នុងខេត្តទាំងមូលទីនោះ ហើយបញ្ជាឱ្យរៀបចំគ្រឿងសាស្ត្រាវុធ សម្រាប់ទាហាន និងអាស្ត្រប្រដាប់គ្រប់ក្លឹបក៏ត្រូវមានប្រដាប់ប្រដាទាំងអស់គឺ ធ្នូ ស្នា ដាវ លំពែង ផ្គាក់ ខែល ។ល។

សកម្មភាពរបស់ទ័ពទូក

ទាហានជើងទឹកជាប់លេខាធិការដ្ឋាន មាននាមខាងលើទៀតគឺ: ទេពអង្គ ទេពរ ទេពរាង។ ពត្រៀមស្លៀកពាក់ នោះត្រូវស្លៀកសំពត់ចងក្បិន ពាក់អាវវែង មានស្បែកស្ពាយក្រវាត់សំពត់ហើយមួកក្រហម ពេលធ្វើដំណើរប្រើទូក ៤០ ឬ ១២ ជំរេះ គ្រឿងសម្ភារៈរបស់ទាហាននោះ គេបានទិញតម្លៃក្រហមនៅកណ្ដាលទូក ហើយមេទ័ពត្រូវមានអ្នកតំណាងការពារក្រហមមួយជាជាង ២ ឬ ជាប់តាមបុណ្យសក្តិរបស់មេទ័ពនោះ។

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

[illegible]

សេចក្តីប្រកាសសកលអំពីសិទ្ធិជនជាតិដើម

(តពីលេខមុន)

មាត្រា១៣

វាក្យខណ្ឌទី ១ : [illegible]

វាក្យខណ្ឌទី ២ : [illegible]

មាត្រា១៤

វាក្យខណ្ឌទី ១ : [illegible]

វាក្យខណ្ឌទី ២ : [illegible] (នៅមានត)

ភាសានិយមរបស់ខ្មែរកម្ពុជាក្រោម

(តពីលេខមុន)

ភាសាខ្មែរកម្ពុជាក្រោម	ភាសាខ្មែរកម្ពុជា
៦១- [illegible]	[illegible]
៦២- [illegible]	[illegible]
៦៣- [illegible]	[illegible]
៦៤- [illegible]	[illegible]
៦៥- [illegible]	[illegible]
៦៦- [illegible]	[illegible]
៦៧- [illegible]	[illegible]
៦៨- [illegible]	[illegible]
៦៩- [illegible]	[illegible]
៧០- [illegible]	[illegible] (នៅមានត)

[illegible]